# ផ្តែរទ្វាររចនាបថកំពង់ព្រះរកឃើញនៅខេត្តកំពង់ធំ

កំពង់ព្រះ គឺជាឈ្មោះប្រាសាទមួយស្ថិតនៅភូមិកំពង់ព្រះ ឃុំផ្អកទ្រូ ស្រុកបរិបូរ ខេត្តកំពង់ឆ្នាំង (រូបលេខ១)។ ដោយសារក្បាច់រចនានៅលើតួប្រាសាទនេះមានភាពល្អឯក និងមានលក្ខណៈខុសពីក្បាច់រចនាបថមុនៗ អ្នកស្រាវជ្រាវក៏សម្រេចកំណត់យកឈ្មោះកំពង់ព្រះជាឈ្មោះរចនាបថសិល្បៈរបស់ខ្មែរ។ លោកស្រី Gilberte De Coral Rémusat បានកំណត់រចនាបថកំពង់ព្រះគិតចាប់ពីពាក់កណ្តាលទី២នៃស.វ.ទី៨។[១] ដោយឡែក លោក Jean Boisselier កំណត់រចនាបថកំពង់ព្រះគិតចាប់ពីឆ្នាំ៧០៦ ដល់ឆ្នាំ៨០០[២] ហើយការដែលលោកកំណត់យកឆ្នាំ៧០៦នេះជាឆ្នាំចាប់ផ្តើមទំនងមកពីលោកយកតាមកាលបរិច្ឆេទនៅក្នុងសិលាចារឹក នៃការសាងសង់ប្រាសាទភូមិប្រាសាទនៅខេត្តកំពង់ធំ ដែលជាប្រាសាទដ៏សំខាន់មួយនៅក្នុងរចនាបថកំពង់ព្រះ។[៣] ប្រាសាទគំរូសំខាន់ៗនៅក្នុងរចនាបថកំពង់ព្រះមានដូចជា ប្រាសាទកំពង់ព្រះ អកយំ ខ្លោងទ្វារខាងលិចប្រាសាទស្រីគ្រប់ល័ក្ខណ៍[៤] ព្រះធាតុក្វាន់ពីរ ត្រពាំងរុន ព្រះស្រី សក្ក ត្រពាំងប្រើស និងប្រាសាទផ្សេងៗទៀត។ នៅក្នុងអត្ថបទនេះ យើងនឹងលើកយកផ្តែរទ្វាររចនាបថកំពង់ព្រះចំនួន ៩ ផ្ទាំង ដែលរកឃើញនៅខេត្តកំពង់ធំយកមកសិក្សាដោយសង្ខេប។

### តើផ្តែរទ្វាររចនាបថកំពង់ព្រះដែលរកឃើញនៅខេត្តកំពង់ធំមានលក្ខណៈដូចម្តេចខ្លះ?

ក្នុងចំណោមផ្តែរទ្វារទាំង ៩ ផ្ទាំង មានផ្តែរទ្វារមួយដែលយើងអាចសន្និដ្ឋានថាមានអាយុកាលចំណាស់ជាងគេ ពោល គឺប្រាសាទភ្នំស្រះខ្ទោ (រូបលេខ២)។ ផ្តែរទ្វារនេះយើងឃើញក្បាច់បន្ទាត់ធ្នូមានរាងផ្តេកសំប៉ែតត្រង់ និងខាងចុងគួចវង់មកខាងលើដូចគូទខ្យង ហើយចុងសងខាងមានចម្លាក់ក្បាលសសរនៅពីក្រោម។ នៅលើក្បាច់បន្ទាត់ធ្នូ មានលម្អជាក្បាច់រាងវង្វង់ (មេដាយ៉ុង) ចំនួន ៣ លម្អដោយរូបទេពផ្សេងៗ ប៉ុន្តែដោយសារសព្វថ្ងៃរលុបខ្លាំងយើងមិនអាចដឹងថាជារូបទេពអ្វីឲ្យប្រាកដឡើយ។ ចំណែក នៅខាងក្រោមគេលម្អជាកម្រងផ្កា ឬកម្រងមាលាធ្លាស់គ្នា ដូចទម្រង់ទូទៅនៃផ្តែរទ្វាររចនាបថសំបូរព្រៃគុក និងព្រៃក្មេង។ ផ្តែរទ្វារនៅប្រាសាទភ្នំស្រះខ្ទោនេះទំនងជាសិល្បៈនៅចុងរចនាបថព្រៃក្មេង ដើមរចនាបថកំពង់ព្រះ នៅរវាងរជ្ជកាលព្រះបាទជ័យវរ្ម័នទី១ ក្នុងស.វ.ទី៧ (គ.ស.៦៥៧-៦៨១)។[៥] ការសន្និដ្ឋាននេះ យើងយោងតាមសិលាចារឹកដែល

---

[១] De Coral Rémusat 1940: 47

[២] Boisselier 1966: 42

[៣] Coedès 1954: 72

[៤] De Coral Rémusat 1940: 47

[៥] ម៉ង់ វ៉ាលី ២០២១: ២៥៥

អត្ថបទដោយៈ ម៉ង់ វ៉ាលី

រកឃើញនៅទីនោះ ដែលចារឡើងនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី១ ដែលរៀបរាប់អំពីព្រះរាជបញ្ជារបស់ព្រះមហាក្សត្រឲ្យសាងសិវលិង្គមួយតម្កល់នៅប្រាសាទ។[៦] ផ្តែរទ្វារមួយទៀត ដែលមានទម្រង់ស្រដៀងគ្នានេះដែរ គឺផ្តែរទ្វារនៅប្រាសាទអណ្តែត ស្រុកកំពង់ស្វាយ (រូបលេខ២៣)។ ចំណុចខុសគ្នានោះ គឺផ្តែរទ្វារនៅប្រាសាទអណ្តែតពុំមានលម្អជាក្បាច់រាងវង្វង់ដែលមានរូបទេពខាងក្នុងលើក្បាច់បន្ទាត់ធ្នូដូចផ្តែរទ្វារភ្នំស្រះខ្ចៅ។ កាលពីឆ្នាំ១៩០២ ជាពេលដែលគេពុំទាន់បង្កើតឱ្យមានការសិក្សាសិល្បៈខ្មែរជារចនាបថនីមួយៗ លោក Lunet De Lajonquière បានកំណត់សម្គាល់ផ្តែរទ្វារនេះស្ថិតនៅក្នុងប្រភេទទី៥។[៧] ក្រោយមក នៅក្នុងឆ្នាំ១៩២៧ លោក Henri Parmentier ដែលជាអ្នកប្រវត្តិសិល្បៈវិទូដ៏ល្បីល្បាញ បានសិក្សាម្តងទៀត និងកំណត់ផ្តែរនេះស្ថិតក្នុងប្រភេទទី២។[៨] លុះមកដល់ឆ្នាំ១៩៧១ លោកស្រី Mireille Bénisti ក៏បានសិក្សាឡើងវិញ និងស្នើថា ផ្នែកខាងចុងរបស់ផ្តែរទ្វារប្រាសាទអណ្តែត កួចវង់ឡើងលើដូចគូទខ្យងដែលបង្ហាញអំពីទម្រង់នៃការចាប់ផ្តើមវិវឌ្ឍទៅរករចនាបថកំពង់ព្រះ។[៩] ម្ល៉ោះហើយ ផ្តែរប្រាសាទអណ្តែត ក៏ទំនងមានអាយុកាលមិនខុសគ្នាប៉ុន្មានពីផ្តែរប្រាសាទភ្នំស្រះខ្ចៅនោះដែរ ពោល គឺអាចនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី១ ឬក្រោយរជ្ជកាលទ្រង់បន្តិច។

ផ្តែរទ្វារចំនួន ២ផ្ទាំងទៀតដែលរកឃើញនៅប្រាសាទតោ ក្នុងតំបន់ប្រាសាទសំបូរព្រៃគុក (រូបលេខ២៤) និងប្រាសាទអំពិលរលំ ស្រុកស្ទោង (រូបលេខ២៥) មានទម្រង់ស្ទើរតែដូចគ្នាតែម្តង។ ផ្តែរទ្វារទាំងពីរនេះ មានក្បាច់បន្ទាត់ធ្នូរាងមូលដូចមែកឈើ កួចជាកង់ៗដោយក្បាច់ផ្ការំដួល ធ្លាស់រំយោលចុះមកក្រោម ដែលផ្នែកខាងចុងមានរាងកោងពត់វង់ចូលក្នុងដូចគូទខ្យង ហើយផ្នែកខាងលើនិងខាងក្រោមលម្អជាសន្ទឹកផ្កានិងរំយោលផ្កា។ ក្នុងឆ្នាំ១៩២៧ លោក Henri Parmentier ធ្លាប់សិក្សានិងកំណត់ផ្តែរទ្វារប្រាសាទអំពិលរលំចូលក្នុងប្រភេទទី២។[១០] នៅក្នុងឆ្នាំ១៩៦៨ លោក Jean Boisselier យល់ថាផ្តែរទ្វារខាងលិចនៃប្រាសាទតោដែលយើងលើកមកសិក្សានេះ មានទម្រង់ជាសិល្បៈចុងរចនាបថកំពង់ព្រះ ដើមរចនាបថគូលែន។[១១] ការដែលលោកសន្និដ្ឋានដូច្នេះ ទំនងមក

---

[៦] ជិត ច័ន្ទកត្តី ២០២០: ៦៧។

[៧] Lajonquière 1902: 259.

[៨] Parmentier 1927: 157.

[៩] Bénisti 1971: 96.

[១០] Parmentier 1927: 154.

[១១] Boisselier 1968: 134.

អត្ថបទដោយៈ ម៉ង់ វ៉ាលី

ពីលោកយល់ថា តួប៉មកណ្តាលនៃប្រាសាទតោនេះសាងសង់ឡើងក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី២ ព្រោះយើងធ្លាប់ដឹងស្រាប់ហើយថា បដិមាតោនៅខាងមុខប្រាសាទមានទម្រង់ដូចតោនៅប្រាសាទថ្មដាប់ (ភ្នំគូលែន) ដែលលោក Philippe Stern យល់ថាជាបដិមាតោនិងប្រាសាទនៅដើមរចនាបថគូលែន ចុងស.វ.ទី៨។[១២] ប៉ុន្តែ មកដល់ឆ្នាំ១៩៧១ លោកស្រី Mireille Bénisti បានសិក្សាផ្តែរទ្វារខាងលិចនៃប្រាសាទតោ និងផ្តែរទ្វារប្រាសាទអំពិលរលំឡើងវិញ ហើយបានសន្និដ្ឋានថា ជាផ្តែរនៅដើមរចនាបថកំពង់ព្រះដែរ។[១៣]

ផ្តែរមួយផ្ទាំងទៀត ដែលអាចរាប់បញ្ចូលថាមានអាយុកាលក្មេងជាងផ្តែរទាំងបួនខាងលើនោះ គឺផ្តែរប្រាសាទភ្នំស្រួច ស្រុកសន្ទុក ដែលសព្វថ្ងៃតម្កល់នៅសារមន្ទីរកំពង់ធំ (រូបលេខ៦)។ ទម្រង់ទូទៅនៃផ្តែរនេះមានលក្ខណៈខុសពីផ្តែរទាំងបួនខាងលើច្រើន ពោល គឺយើងឃើញសិល្បករលម្អជាក្បាច់រាងសន្ទឹកឈើចំនួនប្រាំតម្រៀបគ្នាជាជួរ ដែលនៅខាងចុងមានលម្អក្បាច់ក្បាលសសរដូចរចនាបថសំបូរព្រៃគុក និងព្រៃក្មេងដែរ។ នៅផ្នែកកណ្តាលវិញ សន្ទឹកឈើគេលម្អក្នុងទម្រង់ជារូបក្បាលរាហូ (ព្រះកាល) ហើយផ្នែកខាងក្រោមគេលម្អជាចង្វាយក្បាច់ឆ្លាស់គ្នា។ នៅលើផ្តែរទ្វាររចនាបថកំពង់ព្រះ គេនិយមលម្អជារូបរាហូនៅចំកណ្តាលណាស់ ជាក់ស្តែងដូចឃើញនៅប្រាសាទព្រៃក្មេង (សៀមរាប) និងផ្តែរមួយចំនួនទៀតរកឃើញនៅខេត្តក្រចេះ។[១៤] ផ្តែរប្រាសាទភ្នំស្រួច ទំនងមានអាយុកាលនៅចុងស.វ.ទី៧ ប្រហាក់ប្រហែលផ្តែរទ្វារទាំងបួនខាងលើដែរ។

ផ្តែរទ្វារចំនួន ៤ផ្ទាំង មានទម្រង់ប្រហាក់ប្រហែលគ្នា ហើយអាចក្មេងជាងផ្តែរទាំងប្រាំខាងលើ ពោល គឺផ្តែរទ្វារប្រាសាទគុកព្រះធាតុ ស្រុកស្ទោង (រូបលេខ៧) ផ្តែរប្រាសាទអូរព្រៃខ្នាក់ ស្រុកស្ទោង (រូបលេខ៨) ផ្តែរប្រាសាទត្រពាំងប្រើស (រូបលេខ៩) និងផ្តែរប្រាសាទភូមិប្រាសាទ (រូបលេខ១០)។ យើងឃើញក្បាច់បន្ទាត់ធ្នូផ្តែរប្រាសាទអូរព្រៃខ្នាក់ និងផ្តែរប្រាសាទភូមិប្រាសាទ មានរាងមូលដូចមែកឈើត្រង់ ប៉ុន្តែខុសបន្តិចត្រង់ផ្នែកខាងចុងនៃផ្តែរភូមិប្រាសាទមានរាងពត់វង់ចូលក្នុងដូចគូទខ្យង និងមានសន្ទឹកក្បាច់រាហូនៅចំកណ្តាល តែផ្តែរប្រាសាទអូរព្រៃខ្នាក់ខាងចុងមិនពត់វង់ចូលក្នុង ហើយនៅកណ្តាលពុំមានសន្ទឹកក្បាច់រូបរាហូ។ ផ្តែរទ្វារប្រាសាទភូមិប្រាសាទ មានទម្រង់ដូចគ្នាខ្លាំងនឹងផ្តែរទ្វារប្រាសាទកំពង់ព្រះ ខេត្តកំពង់ឆ្នាំង[១៥] ដែលសាងឡើងនៅរវាងដើមស.វ.ទី៨ នៅ

[១២] Stern 1938: 141.

[១៣] Bénisti 1971: 111.

[១៤] ម៉ង់ វ៉ាលី ២០១៤: ៣៥-៣៦។

[១៥] Bénisti 1971: 100.

ចន្លោះរាជ្យស្តេចជ័យវរ្ម័នទី១ និងព្រះនាងជ័យទេវី។ ដោយឡែក ផ្តែរប្រាសាទគុកព្រះធាតុ និងផ្តែរប្រាសាទត្រពាំងប្រើស មានទម្រង់ដូចគ្នាច្រើន ពោលគឺយើងឃើញក្បាច់បន្ទាត់ធ្នូមានរាងមូលដូចមែកឈើដូចផ្តែរភូមិប្រាសាទដែរ តែមិនត្រង់ពេក គឺមានរាងផាកទៅលើច្រើន ហើយផ្នែកខាងចុងពត់វង់ចូលក្នុងជាគូទខ្យងដូចគ្នា។ ផ្តែរប្រាសាទគុកព្រះធាតុ នៅកណ្តាលមានសន្ទឹកក្បាច់ជារាងរាហូដូចផ្តែរប្រាសាទភូមិប្រាសាទ និងប្រាសាទភ្នំស្រួចដែរ។ ដោយសារទីតាំងប្រាសាទត្រពាំងប្រើសនៅកៀកជាមួយក្រុងសម្ភុបុរ ដែលមានសកម្មភាពខ្លាំងក្នុងស.វ.ទី៨ ទំនងជាផ្តែរនេះអាចមានអាយុកាលនៅស.វ.ទី៨ដែរ ពោល គឺមានភាពដូចគ្នាច្រើនជាមួយផ្តែរទ្វារប្រាសាទព្រះធាតុក្វាន់ពីរ ដែលសិលាចារឹករបស់ចុះបញ្ជីលេខ K.121 ឱ្យកាលបរិច្ឆេទកសាងនៅដើមស.វ.ទី៨។[១៦]

ជារួមមក យើងឃើញថាផ្តែរទ្វារទាំង ៩ផ្ទាំង ដែលរកឃើញនៅខេត្តកំពង់ធំ ដូចបានរៀបរាប់ខាងលើ សុទ្ធសឹងជាផ្តែរទ្វាររបស់ប្រាសាទដែលស្ថិតនៅក្នុងរចនាបថកំពង់ព្រះ។ អ្វីគួរកត់សម្គាល់នោះ ផ្តែរទ្វារខ្លះស្ថិតនៅចុងរចនាបថព្រៃក្មេង ដើមរចនាបថកំពង់ព្រះ ម៉្លោះហើយ អាយុកាលរបស់ផ្តែរនេះទំនងមិនស្ថិតដល់ឆ្នាំ៧០៦ ដូចលោក Jean Boisselier បានចាត់ថ្នាក់ឡើយ ពោលគឺអាចស្ថិតនៅក្នុងរជ្ជកាលស្តេចជ័យវរ្ម័នទី១ ក្នុងគ.ស.៦៥៧ ដល់ ៦៨១ ឬអាចក្រោយរាជ្យទ្រង់បន្តិច។ ដោយឡែក ផ្តែរទ្វារចំនួន ៤ មានផ្តែរទ្វារប្រាសាទភូមិប្រាសាទ អូរព្រៃខ្នាក់ គុកព្រះធាតុ និងត្រពាំងប្រើស អាចស្ថិតនៅក្នុងការចាត់ថ្នាក់របស់លោកដែលចាប់ពីឆ្នាំ៧០៦មក។

---

១៦ Aymonier 1900: 297.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១៖ ប្រាសាទកំពង់ព្រះ ខេត្តកំពង់ឆ្នាំងមើលពីមុខ



រូបលេខ១៖ ប្រាសាទកំពង់ព្រះ ខេត្តកំពង់ឆ្នាំង មើលពីក្រោយ (រូបថត៖ លាក់ ស៊ីផាន់ណា)



រូបលេខ២៖ ផ្តែរប្រាសាទភ្នំស្រះខ្ចៅ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៣៖ ផ្តែរប្រាសាទអណ្តែត



រូបលេខ៤៖ ផ្តែរប្រាសាទតោ តួប៉មកណ្តាល (ផ្តែរខាងលិច)



រូបលេខ៥៖ ផ្តែរប្រាសាទអំពិលរលំ (ប្រភព៖ EFEO)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៦៖ ផ្តែរប្រាសាទភ្នំស្រួច



រូបលេខ២៧៖ ផ្តែរប្រាសាទគុកព្រះធាតុ



រូបលេខ២៨៖ ផ្តែរប្រាសាទអូរព្រៃខ្នាក់

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៩៖ ផ្តែរប្រាសាទត្រពាំងប្រើស



រូបលេខ១០៖ ផ្តែរប្រាសាទភូមិប្រាសាទ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

# ឯកសារយោង

**ម៉ង់ រ៉ាលី**

២០២១, *កំពង់ធំ ប្រវត្តិសាស្ត្រ និងប្រាសាទបុរាណ*, ភ្នំពេញ

២០១៤, *ការវិវត្តចម្លាក់ពហូលើផ្តែរទ្វារក្នុងសិល្បៈខ្មែរសម័យបុរាណ*, ភ្នំពេញ

**ជិត ច័ន្ទកក្តី**

២០២០, *ការសិក្សាស្ថានីយបុរាណនៅក្នុងស្រុកសន្ទុក*, ភ្នំពេញ

**Aymonier, Etienne**

1900, *"Le Cambodge"*, *Tome I, Le royume actuel*, Paris.

**Bénisti, Mireille**

1971, "Recherches sur le premier art khmer, III. Aux confins des styles de Prei Kmeng et de Kampong Preah ", *Arts Asiatiques*, Tome 23, Paris

**Boisselier, Jean**

- 1966, "*Asie du Sud-Est, Le Cambodge* ", Tome I, Paris
- 1968"Les linteaux khmère du VIII$^{e}$ siècle, Nouvelles données sur le style de Kampong Preah ", *Arlibus Asiae*, Tome XXX, Paris

**Coedès, Goerge**

1954, *Inscription du Cambodge*, Tome VI, Hanoi

**Gilberte, De Coral Rémusat**

1940, *L'Art Khmer, Les grandes étapes et son évolution, les éditions d'art et d'histoire*, Paris

**Lunet De Lajonquière**

1902, *Inventaire descriptive des monuments du Cambodge*, Tome I, Paris

**Parmentier, Henri**

1927, *"L'Art Khmér Primitif"*, Tome I, Paris

**Stern, Philippe**

1938, "Le style du Kulen ", *BEFEO*, Tome 38, Paris